ទៀត ត្រូវអនុវត្តតាមសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០១

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

---

រាជធានីភ្នំពេញ ថ្ងៃ ទី ០៣ ខែ មេសា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ១៦ សសរ

## ស្តីពី

## ការបង្កើតគណកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ

~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលខ ០២/នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
~~~

- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញអនុក្រឹត្យលេខ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន

-បានឃើញសេចក្តីប្រកាសលេខ ០១ប្រក. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រងនិងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើរបស់រាជរដ្ឋាភិបាល

-បានឃើញសេចក្តីប្រកាសលេខ ០៦ប្រក. ចុះថ្ងៃទី ២៧ខែ កញ្ញាឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងបញ្ហាទន្រ្ទានកាន់កាប់ដីធ្លី របស់រាជរដ្ឋាភិបាល

-យោងសភាពការចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ការការពារនិងការគ្រប់គ្រងជីវៈចំរុះ សំរាប់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបរិស្ថាននៅកម្ពុជា

សំរេច

**ប្រការ១** : បង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ ដើម្បីពិភាក្សាផ្តល់យោបល់ និងពិនិត្យមើលយុទ្ធសាស្ត្រ និងផែនការសកម្មភាពថ្នាក់ជាតិ ស្តីពីការអភិរក្ស ការប្រើប្រាស់ ការការពារ និងការគ្រប់គ្រងជីវៈចំរុះដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព បរិស្ថាននៅកម្ពុជា ដែលមានសមាសភាពដូចតទៅៈ

| | |
|---|---|
| ១- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តមរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ មួយរូប | អនុប្រធាន |
| ៣- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ មួយរូប | សមាជិក |
| ៤- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងផែនការ មួយរូប | សមាជិក |
| ៥- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម មួយរូប | សមាជិក |
| ៦- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ មួយរូប | សមាជិក |
| ៧- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មួយរូប | សមាជិក |
| ៨- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន មួយរូប | សមាជិក |

៩- ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា មួយរូប សមាជិក

១០- ឯកឧត្តមអគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា សមាជិក

១១- ឯកឧត្តមអគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមួយរូប សមាជិក

១២- តំណាងអភិបាលខេត្ត-ក្រុងដែលពាក់ព័ន្ធ សមាជិក

**ប្រការ២ :**

គណៈកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ មានតួនាទី និងភារកិច្ចដូចតទៅ:

លើកសំណើរគោលនយោបាយ ស្តីពីជីវៈចំរុះជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

- ធ្វើទំនាក់ទំនងជាផ្លូវការវាងរាជរដ្ឋាភិបាលកម្ពុជានិងលេខាធិការដ្ឋាននៃអនុសញ្ញាស្តីជីវៈចំរុះ និងគាំទ្រនូវតួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋាន នៃអនុសញ្ញាស្តីពីជីវៈចំរុះ
- ជ្រើសរើស ឬចាត់តាំង តំណាង ប្រទេស កម្ពុជា ដើម្បីចូលរួមនៅក្នុងសិក្ខាសាលាជីវៈចំរុះ និងសម័យប្រជុំនានារបស់អនុសញ្ញាស្តីពីជីវចំរុះ
- ជំរុញនិងគាំទ្រដល់ការផ្សព្វផ្សាយអនុសញ្ញាស្តីពីជីវៈចំរុះ នៅក្នុង ប្រទេស

-ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ស្តីពីអនុសញ្ញា និងសេចក្តីព្រាងអនុស្សរណៈនានា ដែលទាក់ទង ទៅនិងការអនុវត្តន៍អនុសញ្ញាស្តីពីជីវៈចំរុះ

- ត្រួតពិនិត្យ និងជំរុញលើកិច្ចសហប្រតិបត្តិការវាងស្ថាប័នពាក់ព័ន្ធ លើបញ្ហាជីវៈចំរុះ
- ត្រួតពិនិត្យ និងសំរេចលើការបង្កើតយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ
- ជំរុញការអនុវត្តន៍ ត្រួតពិនិត្យ និងវាយតំលៃលើយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះកំណត់អោយបានច្បាស់ថា យុទ្ធសាស្ត្រ និងផែនការ សកម្មភាពជីវៈចំរុះត្រូវបានបញ្ចូលទៅក្នុង ផែនការសកម្មភាពរបស់ក្រសួង -ស្ថាប័នពាក់ព័ន្ធ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ច ៥ ឆ្នាំរបស់កម្ពុជា
- ត្រួតពិនិត្យ និងជំរុញនូវការបង្កើតគោលនយោបាយស្តីពីជីវៈចំរុះរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ត្រួតពិនិត្យឡើងវិញលើភាពចាំបាច់ជាអាទិភាពនៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះរៀង រាល់ពីរឆ្នាំម្តង ដោយបញ្ចូលនូវសកម្មភាពផ្សេងៗសំរាប់ការប្រើប្រាស់ ការការពារនិងការគ្រប់គ្រងជីវៈចំរុះប្រកបដោយនិរន្តរភាព បរិស្ថាននៅកម្ពុជា

-ត្រួតពិនិត្យនិងកំណត់អោយបានច្បាស់ថារាល់លក្ខខ័ណ្ឌរបស់អ្នកផ្តល់ជំនួយសំរាប់គំរោងដែលពាក់ព័ន្ធ ទៅនឹងជីវៈចំរុះ ត្រូវស្ថិតនៅក្នុងក្របខ័ណ្ឌនៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវៈចំរុះ

-តាមដានការអនុវត្តន៍នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះនិងបញ្ហាជីវៈចំរុះផ្សេងៗ

-ធ្វើសេក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល ហើយចំលងជូនគណៈកម្មាធិការសិទ្ធិមនុស្ស ស្តីពីការអនុវត្តន៍ នៃយុទ្ធសាស្ត្រ និងផែនការសកម្មភាពជីវៈចំរុះ និងបញ្ហាជីវៈចំរុះដទៃទៀត ។

**ប្រការ ៣ :**

បណ្តាសមាជិកគណៈកម្មាធិការជាតិ តំណាងអោយក្រសួង-ស្ថាប័ន ខេត្ត-ក្រុងនានា ត្រូវចូលរួមទទួលខុសត្រូវ ក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិចដែលបានចែងទុកក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ ដើម្បីរាយការណ៍ពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល ។

**ប្រការ ៤ :**

គណៈកម្មាធិការជាតិ គ្រប់គ្រងជីវៈចំរុះ ត្រូវចាត់តាំងលេខាធិការដ្ឋានមួយដែលមានទីតាំងក្នុងក្រសួងបរិស្ថាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី ក្រសួងផែនការ រដ្ឋមន្ត្រីស្រួង ធនធាន ទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួង អប់រំយុវជន និងកីឡា រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែនិថាមពល ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គលេខានៃគណៈ កម្មាធិការ ជាតិទន្លេមេគង្គកម្ពុជានិងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធអភិបាលខេត្ត-ក្រុងត្រូវអនុវត្តនូវសេចក្តី សំរេចនេះ ឱ្យមាន ប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិង ត្រា

**ហ៊ុន សែន**